**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
លេខ...៩៣៣...សហវ.ប្រក.[illegible]

# ប្រកាសអន្តរក្រសួង
## ស្តីពី
## ការផាកពិន័យ ដែលស្ថិតក្រោមសមត្ថកិច្ចរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**រដ្ឋមន្ត្រី**
**ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២០/០០៩ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២៣/០០១ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨២២/០១០ ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម


ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA
mef.gov.kh
t.me/mefcambodia
ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666
info@mef.gov.kh
mef.cabinet@mef.gov.kh

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៧/០១៣ ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីស្តង់ដារកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១១ ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្ម នៃច្បាប់ស្តីពីស្តង់ដារកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០៩/០១៦ ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីមាត្រាសាស្ត្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១០៩/០២២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ៤៨ អនក្រ.បក ចុះថ្ងៃទី៦ ខែមេសា ឆ្នាំ២០២០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- បានឃើញអនុក្រឹត្យលេខ៧២ អនក្រ.បក ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១៨ ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ១ .-**

ការផាកពិន័យ ដែលស្ថិតក្រោមសមត្ថកិច្ចរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ត្រូវបានរៀបចំជាបញ្ជីផាកពិន័យដែលមានរាយលម្អិតអំពីប្រភេទបទល្មើស និងកម្រិតទឹកប្រាក់ពិន័យទៅតាមប្រភេទបទល្មើសនីមួយៗ ដូចមានចែងក្នុងឧបសម្ព័ន្ធនៃប្រកាសអន្តរក្រសួងនេះ។

**ប្រការ២ .-**

ការផាកពិន័យលើប្រភេទបទល្មើសនីមួយៗ ត្រូវអនុវត្តតាមនីតិវិធីដែលកំណត់ដោយរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។

**ប្រការ៣ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសអន្តរក្រសួងនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៤ .-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គនាយក អគ្គាធិការ ប្រធាននាយកដ្ឋាន និងប្រធានអង្គភាពពាក់ព័ន្ធនៃក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួងនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ អាទិត្យ ៦កើត ខែកត្តិក ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែវិច្ឆិកា ឆ្នាំ២០២៣

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**រដ្ឋមន្ត្រី**

**ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍**

**ហេម វណ្ណឌី**

**កន្លែងទទួល :**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អាជ្ញាធរសវនកម្មជាតិ
- អង្គភាពប្រឆាំងអំពើពុករលួយ
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- រដ្ឋបាលរាជធានី ខេត្ត
- ដូចប្រការ៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**បញ្ជីផាកពិន័យ ដែលស្ថិតក្នុងភារកិច្ចរបស់អង្គភាពរដ្ឋបាលកណ្តាលនៃក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍**

| លេខរៀងបទល្មើស | | ប្រភេទបទល្មើស | កម្រិតទឹកប្រាក់ដែលត្រូវពិន័យ (រៀល) |
|---|---|---|---|
| | ក. | **បទល្មើសទូទៅ** | |
| ១ | ១- | ការពិន័យលើការយឺតយ៉ាវចំពោះការបង់កម្រៃសេវាប្រចាំឆ្នាំ (ហួសរយៈពេល ៦ខែ) ដើម្បីរក្សាសុពលភាពសំណុំលិខិតស្នើសុំប្រកាសនីយបត្រតក្កកម្ម និងប្រកាសនីយបត្រតក្កកម្ម (គិតក្នុង១ថ្ងៃ) | ៥០០ |
| ២ | ២- | ការពិន័យលើការយឺតយ៉ាវចំពោះការបង់កម្រៃសេវាប្រចាំឆ្នាំ (ហួសរយៈពេល ៦ខែ) ដើម្បីរក្សាសុពលភាពសំណុំលិខិតស្នើសុំវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ (គិតក្នុង១ថ្ងៃ) | ៥០០ |
| ៣ | ៣- | ការពិន័យលើការយឺតយ៉ាវចំពោះការបង់កម្រៃសេវាប្រចាំឆ្នាំ (ហួសរយៈពេល ៦ខែ)ដើម្បីរក្សាសុពលភាពការពារពូជថ្មីនៃដំណាំ (គិតក្នុង១ថ្ងៃ) | ៥០០ |
| ៤ | ៤- | ពិន័យលើការយឺតយ៉ាវចំពោះការបង់កម្រៃនៃការចុះបញ្ជីគំនូរឧស្សាហកម្មសាឡើងវិញ ហួសរយៈពេល ៦ខែ (គិតក្នុង១ថ្ងៃ) | ៥០០ |
| | ខ. | **បទល្មើសដែលចែងក្នុងច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម** | |
| | ១- | ក្នុងករណីបង្កើតសិប្បកម្ម ដែលតម្រូវឱ្យស្នើចុះបញ្ជី ដោយពុំបានជូនដំណឹងជាលាយលក្ខណ៍អក្សរទៅអាជ្ញាធរមូលដ្ឋាន និងពុំបានធ្វើការចុះបញ្ជីនៅមន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍រាជធានី ខេត្ត ដែលខ្លួនបានបោះទីតាំងក្នុងរយៈពេល ០៧ថ្ងៃ ក្រោយថ្ងៃដំណើរការ (មាត្រា៤៣) | |
| ៥ | - | ផាកពិន័យលើកទី១ | ៥០០ ០០០ |
| ៦ | - | ផាកពិន័យលើកទី២ (ករណីមិនគោរពតាមការជូនដំណឹងលើកទី១) | ១ ៥០០ ០០០ |
| ៧ | - | ផាកពិន័យលើកចុងក្រោយ (ករណីមិនគោរពតាមការជូនដំណឹងលើកទី២) | ២ ៥០០ ០០០ |
| | ២- | ក្នុងករណីបង្កើតប្រភេទសិប្បកម្ម ដែលចែងដោយប្រកាសរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ដោយគ្មានការអនុញ្ញាត (មាត្រា៤៣) | |
| ៨ | - | ផាកពិន័យលើកទី១ | ១ ០០០ ០០០ |
| ៩ | - | ផាកពិន័យលើកទី២ (ករណីមិនគោរពតាមការជូនដំណឹងលើកទី១) | ៣ ០០០ ០០០ |
| ១០ | - | ផាកពិន័យលើកចុងក្រោយ (ករណីមិនគោរពតាមការជូនដំណឹងលើកទី២) | ៥ ០០០ ០០០ |
| | ៣- | ក្នុងករណីពង្រីក ឬបង្កើតសាខា ឬផ្លាស់ប្តូរទីតាំងរោងចក្រពុំមានលិខិតអនុញ្ញាតពីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ (មាត្រា៤៤) | |
| ១១ | - | ផាកពិន័យលើកទី១ | ២ ០០០ ០០០ |
| ១២ | - | ផាកពិន័យលើកទី២ (ករណីមិនគោរពតាមការជូនដំណឹងលើកទី១) | ៦ ០០០ ០០០ |
| ១៣ | - | ផាកពិន័យលើកចុងក្រោយ (ករណីមិនគោរពតាមការជូនដំណឹងលើកទី២) | ១០ ០០០ ០០០ |
| | ៤- | ក្នុងករណីប្តូរម្ចាស់រោងចក្រ ម្ចាស់រោងចក្រថ្មីពុំបានធ្វើការសុំទទួលស្គាល់ជាម្ចាស់រោងចក្រពីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ក្នុងរយៈពេល ១០ថ្ងៃនៃថ្ងៃធ្វើការ ចាប់ពីថ្ងៃដែលខ្លួនបានទទួលសិទ្ធជាម្ចាស់រោងចក្រថ្មី (មាត្រា៤៤) | |
| ១៤ | - | ផាកពិន័យលើកទី១ | ២ ០០០ ០០០ |
| ១៥ | - | ផាកពិន័យលើកទី២ (ករណីមិនគោរពតាមការជូនដំណឹងលើកទី១) | ៦ ០០០ ០០០ |
| ១៦ | - | ផាកពិន័យលើកចុងក្រោយ (ករណីមិនគោរពតាមការជូនដំណឹងលើកទី២) | ១០ ០០០ ០០០ |
| | ៥- | ក្នុងករណីម្ចាស់រោងចក្រទទួលមរណភាព ឬអសមត្ថភាពតាមផ្លូវច្បាប់ អ្នកទទួលសិទ្ធិគ្រប់គ្រងបន្ត ពុំបានធ្វើពាក្យសុំទទួលស្គាល់ជាម្ចាស់រោងចក្រពីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ក្នុងរយៈពេល ៤៥ថ្ងៃនៃថ្ងៃធ្វើការ ចាប់ពីថ្ងៃដែលម្ចាស់រោងចក្រដើមទទួលមរណភាព ឬបាត់បង់សមត្ថភាពតាមផ្លូវច្បាប់ (មាត្រា៤៤) | |
| ១៧ | - | ផាកពិន័យលើកទី១ | ២ ០០០ ០០០ |
| ១៨ | - | ផាកពិន័យលើកទី២ (ករណីមិនគោរពតាមការជូនដំណឹងលើកទី១) | ៦ ០០០ ០០០ |
| ១៩ | - | ផាកពិន័យលើកចុងក្រោយ (ករណីមិនគោរពតាមការជូនដំណឹងលើកទី២) | ១០ ០០០ ០០០ |
| | ៦- | ក្នុងករណីម្ចាស់រោងចក្រ ពុំបានជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ក្នុងរយៈពេលមួយខែ មុនថ្ងៃដែលរោងចក្របញ្ឈប់ដំណើរការជាស្ថាពរ (មាត្រា៤៤) | |
| ២០ | - | ផាកពិន័យលើកទី១ | ២ ០០០ ០០០ |
| ២១ | - | ផាកពិន័យលើកទី២ (ករណីមិនគោរពតាមការជូនដំណឹងលើកទី១) | ៦ ០០០ ០០០ |
| ២២ | - | ផាកពិន័យលើកចុងក្រោយ (ករណីមិនគោរពតាមការជូនដំណឹងលើកទី២) | ១០ ០០០ ០០០ |

| លេខរៀងបទល្មើស | ប្រភេទបទល្មើស | | កម្រិតទឹកប្រាក់ដែលត្រូវពិន័យ (រៀល) |
|---|---|---|---|
| | ៧- | ក្នុងករណីម្ចាស់រោងចក្រ ពុំបានតាំងបង្ហាញប្រកាសបង្កើតរោងចក្រ និងលិខិតអនុញ្ញាតទាំងឡាយជាចំហនៅកន្លែងសមស្របណាមួយ ដែលងាយមើលឃើញក្នុងរោងចក្រ (មាត្រា៤៤) | |
| ២៣ | - | ផាកពិន័យលើកទី១ | ២ 000 000 |
| ២៤ | - | ផាកពិន័យលើកទី២ (ករណីមិនគោរពតាមការជូនដំណឹងលើកទី១) | ៦ 000 000 |
| ២៥ | - | ផាកពិន័យលើកចុងក្រោយ (ករណីមិនគោរពតាមការជូនដំណឹងលើកទី២) | ១0 000 000 |
| | ៨- | ក្នុងករណីបាត់បង់ប្រកាសរោងចក្រ ឬ/និងលិខិតអនុញ្ញាតទាំងឡាយ ម្ចាស់រោងចក្រពុំបានធ្វើពាក្យសុំប្រកាស ឬលិខិតជំនួសមួយទៀត មកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ក្នុងរយៈពេល ១៥ថ្ងៃ គិតពីថ្ងៃបាត់បង់ (មាត្រា៤៤) | |
| ២៦ | - | ផាកពិន័យលើកទី១ | ២ 000 000 |
| ២៧ | - | ផាកពិន័យលើកទី២ (ករណីមិនគោរពតាមការជូនដំណឹងលើកទី១) | ៦ 000 000 |
| ២៨ | - | ផាកពិន័យលើកចុងក្រោយ (ករណីមិនគោរពតាមការជូនដំណឹងលើកទី២) | ១0 000 000 |
| | ៩- | ក្នុងករណីរោងចក្រ ពុំមានឈ្មោះរោងចក្រ ហើយស្លាកឈ្មោះពុំបានសរសេរជាអក្សរខ្មែរ មានទំហំធំជាង នៅពីលើអក្សរផ្សេងៗទៀត ពុំបានលើកបង្ហាញស្លាកឈ្មោះ រោងចក្ររបស់ខ្លួននៅកន្លែងដែលងាយមើលឃើញ នៅខាងមុខរោងចក្រ (មាត្រា៤៤)។ ម្ចាស់រោងចក្រពុំបានផ្តល់ឱ្យបានត្រឹមត្រូវនូវទិន្នន័យ និងរបាយការណ៍ចាំបាច់នានាតាមការកំណត់របស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ (មាត្រា៤៧)។ ការបង្កើតរោងចក្រដោយពុំមានប្រកាសអនុញ្ញាតបង្កើតរោងចក្រ(មាត្រា៤៩ថ្មី)។ | |
| ២៩ | - | ផាកពិន័យលើកទី១ | ២ 000 000 |
| ៣០ | - | ផាកពិន័យលើកទី២ (ករណីមិនគោរពតាមការជូនដំណឹងលើកទី១) | ៦ 000 000 |
| ៣១ | - | ផាកពិន័យលើកចុងក្រោយ (ករណីមិនគោរពតាមការជូនដំណឹងលើកទី២) | ១0 000 000 |
| ៣២ | - | ផាកពិន័យតាមមាត្រា៤៧ (ករណីរឹងរូសពុំអនុវត្តតាមការផាកពិន័យទាំងបីខាងលើ) | ៥0 000 000 |
| | ១០- | ក្នុងករណីផ្លាស់ប្តូរឈ្មោះរោងចក្រ ដោយគ្មានការយល់ព្រមពីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ (មាត្រា៤៨) | |
| ៣៣ | - | ផាកពិន័យលើកទី១ | ២ 000 000 |
| ៣៤ | - | ផាកពិន័យលើកទី២ (ករណីមិនគោរពតាមការជូនដំណឹងលើកទី១) | ៦ 000 000 |
| ៣៥ | - | ផាកពិន័យលើកចុងក្រោយ (ករណីមិនគោរពតាមការជូនដំណឹងលើកទី២) | ១0 000 000 |
| | ១១- | ក្នុងករណីមានឧប្បត្តិហេតុ ឬគ្រោះថ្នាក់នៅក្នុងរោងចក្រដែលបណ្តាលឱ្យរោងចក្រត្រូវផ្អាកដំណើរការទាំងស្រុង លើសពី ៧ថ្ងៃ ហើយម្ចាស់ ឬអ្នកគ្រប់គ្រងរោងចក្រ ពុំបានជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ក្នុងរយៈពេល១០ថ្ងៃ បន្ទាប់ពីថ្ងៃកើតហេតុ (មាត្រា៤៤) | |
| ៣៦ | - | មានឧប្បត្តិហេតុកើតឡើងតែពុំមានគ្រោះថ្នាក់ | ២ 000 000 |
| ៣៧ | - | មានឧប្បត្តិហេតុកើតឡើងអាចបង្កគ្រោះថ្នាក់ | ៦ 000 000 |
| ៣៨ | - | មានឧប្បត្តិហេតុហើយបង្កគ្រោះថ្នាក់ | ១0 000 000 |
| | ១២- | ក្នុងករណីមិនមានប្រព័ន្ធបង្ការអគ្គីភ័យ ដែលរួមមាន ប្រព័ន្ធប្រកាសភាពអាសន្ន និងមធ្យោបាយសម្រាប់ពន្លត់អគ្គីភ័យ, សញ្ញាប្រយ័ត្នអគ្គីភ័យនៅកន្លែងដែលចាំបាច់, ទ្វារសង្គ្រោះមានយ៉ាងតិចបំផុតចំនួនពីរនៅតាមជាន់នីមួយៗ, ផ្លូវសង្គ្រោះសម្រាប់រថយន្តពន្លត់អគ្គីភ័យ, មធ្យោបាយរំដោះខ្លួនផ្សេងៗទៀត, ប្លង់បំព្រួញសម្រាប់ជម្លៀសខ្លួនពេលមានអាសន្ន (មាត្រា៤៦) | |
| ៣៩ | - | ផាកពិន័យលើកទី១ | ២ 000 000 |
| ៤០ | - | ផាកពិន័យលើកទី២ (ករណីមិនគោរពតាមការជូនដំណឹងលើកទី១) | ៦ 000 000 |
| ៤១ | - | ផាកពិន័យលើកចុងក្រោយ (ករណីមិនគោរពតាមការជូនដំណឹងលើកទី២) | ១0 000 000 |
| | ១៣- | ក្នុងករណីម៉ាស៊ីន ឬផ្នែកម៉ាស៊ីនដែលអាចបង្កឱ្យមានគ្រោះថ្នាក់ជាយថាហេតុមិនមានគម្រប ឬឧបករណ៍ការពារ (មាត្រា៤៦) | |
| ៤២ | - | ផាកពិន័យលើកទី១ | ២ 000 000 |
| ៤៣ | - | ផាកពិន័យលើកទី២ (ករណីមិនគោរពតាមការជូនដំណឹងលើកទី១) | ៦ 000 000 |
| ៤៤ | - | ផាកពិន័យលើកចុងក្រោយ (ករណីមិនគោរពតាមការជូនដំណឹងលើកទី២) | ១0 000 000 |
| | ១៤- | ក្នុងករណីមិនមានសញ្ញាបង្ហាញប្រាប់ប្រយ័ត្នគ្រោះថ្នាក់ ឬបំរាមនៅកន្លែងដែលមានគ្រោះថ្នាក់ (មាត្រា៤៦) | |
| ៤៥ | - | ផាកពិន័យលើកទី១ | ២ 000 000 |
| ៤៦ | - | ផាកពិន័យលើកទី២ (ករណីមិនគោរពតាមការជូនដំណឹងលើកទី១) | ៦ 000 000 |
| ៤៧ | - | ផាកពិន័យលើកចុងក្រោយ (ករណីមិនគោរពតាមការជូនដំណឹងលើកទី២) | ១0 000 000 |
| | ១៥- | ក្នុងករណីប្រើប្រាស់ជាតិផ្ទុះ គ្រឿងឆេះ ជាតិពុល គីមីគ្រោះថ្នាក់ ឬឧស្ម័នក្នុងផលិតកម្មមិនបានប្រតិបត្តិតាមលក្ខណៈបច្ចេកទេសដែលធានាបាននូវសុវត្ថិភាព (មាត្រា៤៦) | |
| ៤៨ | - | ផាកពិន័យលើកទី១ | ២ 000 000 |
| ៤៩ | - | ផាកពិន័យលើកទី២ (ករណីមិនគោរពតាមការជូនដំណឹងលើកទី១) | ៦ 000 000 |
| ៥០ | - | ផាកពិន័យលើកចុងក្រោយ (ករណីមិនគោរពតាមការជូនដំណឹងលើកទី២) | ១0 000 000 |

| លេខរៀងបទល្មើស | | ប្រភេទបទល្មើស | កម្រិតទឹកប្រាក់ដែលត្រូវពិន័យ (រៀល) |
|---|---|---|---|
| | ១៦- | ក្នុងករណីឡចំហាយប្រព័ន្ធ ប្រើប្រាស់ចំហាយឧបករណ៍ ឬ ធុងដែលប្រើសំពាធខ្ពស់មិនមានការត្រួតពិនិត្យ និងអនុញ្ញាតពីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍មុនពេលដំណើការ (មាត្រា៤៦) | |
| ៥១ | - | ជាកពិន័យលើកទី១ | ២ ០០០ ០០០ |
| ៥២ | - | ជាកពិន័យលើកទី២ (ករណីមិនគោរពតាមការជូនដំណឹងលើកទី១) | ៦ ០០០ ០០០ |
| ៥៣ | - | ជាកពិន័យលើកចុងក្រោយ (ករណីមិនគោរពតាមការជូនដំណឹងលើកទី២) | ១០ ០០០ ០០០ |
| | គ. | **បទល្មើសដែលចែងក្នុងច្បាប់ ស្តីពីស្តង់ដារកម្ពុជា និងច្បាប់វិសោធនកម្ម** | |
| | ១- | ការប្រើប្រាស់ពាណិជ្ជសញ្ញា ដូចគ្នាទៅនឹងសញ្ញាស្តង់ដារ ឬស្ទើរតែដូចគ្នាទាំងស្រុងធ្វើឱ្យច្រឡំគ្នាទៅនឹងសញ្ញាស្តង់ដារ (មាត្រា៥០.៦ ថ្មី) | |
| ៥៤ | - | ការប្រើប្រាស់ពាណិជ្ជសញ្ញាស្រដៀងគ្នាទៅនឹងសញ្ញាស្តង់ដារ | ២ ០០០ ០០០ |
| ៥៥ | - | ការប្រើប្រាស់ពាណិជ្ជសញ្ញាដូចគ្នាទាំងស្រុងទៅនឹងសញ្ញាស្តង់ដារ | ៦ ០០០ ០០០ |
| ៥៦ | - | បទល្មើសត្រូវបានពិន័យរួច តែនៅបន្តប្រព្រឹត្តជាថ្មី (ករណីមិនរាងចាល តាមមាត្រា៦៤) | ពិន័យទ្វេដង |
| | ២- | ការមិនបានដាក់តាំងអាជ្ញាបណ្ណ ឬមិនបានសុំទុតិយតា ឬមិនបានសុំអាជ្ញាបណ្ណថ្មី (មាត្រា៥១ ថ្មី) | |
| ៥៧ | - | ការមិនបានដាក់តាំងអាជ្ញាបណ្ណ | ៥០០ ០០០ |
| ៥៨ | - | មិនបានសុំទុតិយតា | ១ ០០០ ០០០ |
| ៥៩ | - | មិនបានសុំអាជ្ញាបណ្ណថ្មី | ២ ០០០ ០០០ |
| ៦០ | - | បទល្មើសត្រូវបានពិន័យរួច តែនៅបន្តប្រព្រឹត្តជាថ្មី (ករណីមិនរាងចាល តាមមាត្រា៦៤) | ពិន័យទ្វេដង |
| | ៣- | ការផ្សព្វផ្សាយពាណិជ្ជកម្មអំពីការទទួលវិញ្ញាបនបត្របញ្ជាក់ប្រព័ន្ធណាមួយ ដោយមិនបានចុះបញ្ជី និងទទួលទិដ្ឋាការ (មាត្រា៥២ ថ្មី) | |
| ៦១ | - | ការផ្សព្វផ្សាយរយៈពេលតិចជាង ៦ខែ | ១ ០០០ ០០០ |
| ៦២ | - | ការផ្សព្វផ្សាយរយៈពេលចាប់ពី ៦ខែ ឡើងទៅ | ២ ០០០ ០០០ |
| ៦៣ | - | បទល្មើសត្រូវបានពិន័យរួច តែនៅបន្តប្រព្រឹត្តជាថ្មី (ករណីមិនរាងចាល តាមមាត្រា៦៤) | ពិន័យទ្វេដង |
| | ៤- | ការធ្វើអាជីវកម្មដោយប្រើឈ្មោះដែលមានពាក្យ "ស្តង់ដារកម្ពុជា" ឬ អក្សរកាត់ "ISC" (មាត្រា៥៣ ថ្មី) | |
| ៦៤ | - | ការធ្វើអាជីវកម្មដោយប្រើឈ្មោះដែលមានពាក្យ "ស្តង់ដារកម្ពុជា" ឬ អក្សរកាត់ "ISC" ដោយគ្មានការអនុញ្ញាតពីវិទ្យាស្ថានស្តង់ដារកម្ពុជា | ១ ០០០ ០០០ |
| ៦៥ | - | ករណីមិនអនុវត្តតាមការណែនាំក្រោយរយៈពេល ៦ ខែ | ២ ០០០ ០០០ |
| ៦៦ | - | បទល្មើសត្រូវបានពិន័យរួច តែនៅបន្តប្រព្រឹត្តជាថ្មី (ករណីមិនរាងចាល តាមមាត្រា៦៤) | ពិន័យទ្វេដង |
| | ៥- | ការមិនបានស្នើសុំអាជ្ញាបណ្ណឡើងវិញ ពេលមានការកំណត់ស្តង់ដារថ្មី ឬ ប្រើហួសកាលបរិច្ឆេទកំណត់ (មាត្រា៥៤ ថ្មី) | |
| ៦៧ | - | ការមិនសុំអាជ្ញាបណ្ណឡើងវិញរយៈពេល ៦ខែ ក្រោយស្តង់ដារថ្មីចូលជាធរមាន | ២ ៥០០ ០០០ |
| ៦៨ | - | ករណីមិនគោរពតាមកិច្ចសន្យាលើកទី១ | ៥ ០០០ ០០០ |
| ៦៩ | - | ការមិនមកបន្តអាជ្ញាបណ្ណសម្រាប់ប្រើសញ្ញាបញ្ជាក់ផលិតផល | ២ ៥០០ ០០០ |
| ៧០ | - | បទល្មើសត្រូវបានពិន័យរួច តែនៅបន្តប្រព្រឹត្តជាថ្មី (ករណីមិនរាងចាល តាមមាត្រា៦៤) | ពិន័យទ្វេដង |
| | ៦- | ការផលិត កែច្នៃ ឬនាំចូលផលិតផល ឬផ្សព្វផ្សាយពាណិជ្ជកម្មលក់ ឬលក់ផលិតផលណាមួយដែលមានបិទសញ្ញាស្តង់ដារក្លែងបន្លំ ឬវិញ្ញាបនបត្របញ្ជាក់ប្រព័ន្ធ ឬសញ្ញាបញ្ជាក់ប្រព័ន្ធក្លែងបន្លំ (មាត្រា៥៥ ថ្មី និងមាត្រា៥៦ ថ្មី) | |
| ៧១ | - | ការបន្លំក្នុងរយៈពេលមិនលើស ៦ខែ | ៣ ០០០ ០០០ |
| ៧២ | - | ការបន្លំលើសពីរយៈពេល ៦ខែ | ៦ ០០០ ០០០ |
| ៧៣ | - | បទល្មើសត្រូវបានពិន័យរួច តែនៅបន្តប្រព្រឹត្តជាថ្មី (ករណីមិនរាងចាល តាមមាត្រា៦៤) | ពិន័យទ្វេដង |
| | ៧- | ការបោះពុម្ព ឬ ថតចម្លងឯកសារស្តង់ដារកម្ពុជា ដោយគ្មានការអនុញ្ញាត (មាត្រា៥៨ ថ្មី) | |
| ៧៤ | - | ការបោះពុម្ព ឬ ថតចម្លងឯកសារស្តង់ដារកម្ពុជា ដោយគ្មានការអនុញ្ញាត ក្នុងគោលបំណងផ្សេងក្រៅពាណិជ្ជកម្ម | ៣ ០០០ ០០០ |
| ៧៥ | - | ការបោះពុម្ព ឬ ថតចម្លងឯកសារស្តង់ដារកម្ពុជា ដោយគ្មានការអនុញ្ញាត ក្នុងគោលបំណងធ្វើពាណិជ្ជកម្ម | ៦ ០០០ ០០០ |
| ៧៦ | - | បទល្មើសត្រូវបានពិន័យរួច តែនៅបន្តប្រព្រឹត្តជាថ្មី (ករណីមិនរាងចាល តាមមាត្រា៦៤) | ពិន័យទ្វេដង |
| | ៨- | ការមិនមានបិទសញ្ញាស្តង់ដារ ឬ គ្មានអាជ្ញាបណ្ណ ឬមិនអនុលោមតាមស្តង់ដារប្រភេទបទប្បញ្ញត្តិបច្ចេកទេសលើផលិតផល (មាត្រា៥៩ ថ្មី) | |
| ៧៧ | - | មិនបានបិទសញ្ញាស្តង់ដារលើផលិតផលដែលទទួលបានអាជ្ញាបណ្ណសម្រាប់ប្រើសញ្ញាបញ្ជាក់ផលិតផលលើសរយៈពេល ៦ខែ | ៤ ០០០ ០០០ |
| ៧៨ | - | មិនបានបិទសញ្ញាស្តង់ដារលើផលិតផលដែលទទួលបានអាជ្ញាបណ្ណសម្រាប់ប្រើសញ្ញាបញ្ជាក់ផលិតផលលើសរយៈពេល ៩ខែ | ៨ ០០០ ០០០ |

| លេខរៀងបទល្មើស | | ប្រភេទបទល្មើស | កម្រិតទឹកប្រាក់ដែលត្រូវពិន័យ (រៀល) |
|---|---|---|---|
| | ៩- | គ្មានអាជ្ញាបណ្ណសម្រាប់ប្រើសញ្ញាបញ្ជាក់ផលិតផល (ករណីមិនទាន់បានដាក់ពាក្យស្នើសុំ) | |
| ៧៩ | - | សិប្បកម្ម (ដើមទុនតិចជាង ឬស្មើ ៥០ ០០០ដុល្លារអាមេរិក) | ៦ ០០០ ០០០ |
| ៨០ | - | រោងចក្រខ្នាតតូច (ដើមទុនលើសពី ៥០ ០០០ដុល្លារអាមេរិក ដល់ ៥០០ ០០០ដុល្លារអាមេរិក) | ១២ ០០០ ០០០ |
| ៨១ | - | រោងចក្រខ្នាតមធ្យម (ដើមទុនលើសពី ៥០០ ០០០ដុល្លារអាមេរិក ដល់ ១ ០០០ ០០០ដុល្លារអាមេរិក) | ១៨ ០០០ ០០០ |
| ៨២ | - | រោងចក្រខ្នាតធំ (ដើមទុនលើសពី ១ ០០០ ០០០ដុល្លារអាមេរិក) | ២៤ ០០០ ០០០ |
| ៨៣ | - | បទល្មើសត្រូវបានពិន័យរួច តែនៅបន្តប្រព្រឹត្តជាថ្មី (ករណីមិនរាងចាល តាមមាត្រា៦៤) | ពិន័យទ្វេដង |
| | ១០- | មិនអនុលោមតាមស្តង់ដារប្រភេទបទប្បញ្ញត្តិបច្ចេកទេសលើផលិតផល (ករណីមានអាជ្ញាបណ្ណ) | |
| ៨៤ | - | សិប្បកម្ម (ដើមទុនតិចជាង ឬស្មើ ៥០ ០០០ដុល្លារអាមេរិក) | ៣ ០០០ ០០០ |
| ៨៥ | - | រោងចក្រខ្នាតតូច (ដើមទុនលើសពី ៥០ ០០០ដុល្លារអាមេរិក ដល់ ៥០០ ០០០ដុល្លារអាមេរិក) | ៦ ០០០ ០០០ |
| ៨៦ | - | រោងចក្រខ្នាតមធ្យម (ដើមទុនលើសពី ៥០០ ០០០ដុល្លារអាមេរិក ដល់ ១ ០០០ ០០០ដុល្លារអាមេរិក) | ៩ ០០០ ០០០ |
| ៨៧ | - | រោងចក្រខ្នាតធំ (ដើមទុនលើសពី ១ ០០០ ០០០ដុល្លារអាមេរិក) | ១២ ០០០ ០០០ |
| ៨៨ | - | បទល្មើសត្រូវបានពិន័យរួច តែនៅបន្តប្រព្រឹត្តជាថ្មី (ករណីមិនរាងចាល តាមមាត្រា៦៤) | ពិន័យទ្វេដង |
| | ១១- | ការប្រើ ឬបិទសញ្ញាស្តង់ដារលើអាជ្ញាបណ្ណដែលត្រូវបានលុបចោល ឬ ព្យួរ ឬ ដកហូត (មាត្រា៦០) | |
| ៨៩ | - | សិប្បកម្ម (ដើមទុនតិចជាង ឬស្មើ ៥០ ០០០ដុល្លារអាមេរិក) | ៦ ០០០ ០០០ |
| ៩០ | - | រោងចក្រខ្នាតតូច (ដើមទុនលើសពី ៥០ ០០០ដុល្លារអាមេរិក ដល់ ៥០០ ០០០ដុល្លារអាមេរិក) | ១២ ០០០ ០០០ |
| ៩១ | - | រោងចក្រខ្នាតមធ្យម (ដើមទុនលើសពី ៥០០ ០០០ដុល្លារអាមេរិក ដល់ ១ ០០០ ០០០ដុល្លារអាមេរិក) | ១៨ ០០០ ០០០ |
| ៩២ | - | រោងចក្រខ្នាតធំ (ដើមទុនលើសពី ១ ០០០ ០០០ដុល្លារអាមេរិក) | ២៤ ០០០ ០០០ |
| ៩៣ | - | បទល្មើសត្រូវបានពិន័យរួច តែនៅបន្តប្រព្រឹត្តជាថ្មី (ករណីមិនរាងចាល តាមមាត្រា៦៤) | ពិន័យទ្វេដង |
| | ១២- | ការក្លែងប្រើប្រាស់វិញ្ញាបនបត្រប្រព័ន្ធគ្រប់គ្រងណាមួយ ដែលត្រូវបានព្យួរ ឬដកហូត (មាត្រា៦១) | |
| ៩៤ | - | សិប្បកម្ម (ដើមទុនតិចជាង ឬស្មើ ៥០ ០០០ដុល្លារអាមេរិក) | ៦ ០០០ ០០០ |
| ៩៥ | - | រោងចក្រខ្នាតតូច (ដើមទុនលើសពី ៥០ ០០០ដុល្លារអាមេរិក ដល់ ៥០០ ០០០ដុល្លារអាមេរិក) | ១២ ០០០ ០០០ |
| ៩៦ | - | រោងចក្រខ្នាតមធ្យម (ដើមទុនលើសពី ៥០០ ០០០ដុល្លារអាមេរិក ដល់ ១ ០០០ ០០០ដុល្លារអាមេរិក) | ១៨ ០០០ ០០០ |
| ៩៧ | - | រោងចក្រខ្នាតធំ (ដើមទុនលើសពី ១ ០០០ ០០០ដុល្លារអាមេរិក) | ២៤ ០០០ ០០០ |
| ៩៨ | - | បទល្មើសត្រូវបានពិន័យរួច តែនៅបន្តប្រព្រឹត្តជាថ្មី (ករណីមិនរាងចាល តាមមាត្រា៦៤) | ពិន័យទ្វេដង |
| | ១៣- | ជនណាដែលរារាំងមន្ត្រីអធិការកិច្ចក្នុងពេលបំពេញភារកិច្ច (មាត្រា៦៥ ថ្មី) | |
| ៩៩ | - | ការរារាំងតាមរយៈការមិនផ្តល់ព័ត៌មាន ឬ មិនផ្តល់ឯកសារចាំបាច់ណាមួយ | ២ ០០០ ០០០ |
| ១០០ | - | ការរារាំងតាមរយៈការមិនផ្តល់កិច្ចសហការ (មិនអនុញ្ញាតឱ្យមន្ត្រីអធិការកិច្ចអនុវត្តមុខងារ) | ៥ ០០០ ០០០ |
| ១០១ | - | បទល្មើសត្រូវបានពិន័យរួច តែនៅបន្តប្រព្រឹត្តជាថ្មី (ករណីមិនរាងចាល តាមមាត្រា៦៤) | ពិន័យទ្វេដង |
| | ១៤- | ជនណាដែលក្លែងបន្លំខ្លួនជាមន្ត្រីអធិការកិច្ច (មាត្រា៦៦ ថ្មី) | |
| ១០២ | - | ការបន្លំខ្លួនដោយពុំមានប្រើប្រាស់មធ្យោបាយគម្រាមកំហែង ឬអំពើហឹង្សាណាមួយ | ១ ០០០ ០០០ |
| ១០៣ | - | ការបន្លំខ្លួនដោយមានការគំរាមកំហែង ឬ ប្រើអំពើហឹង្សាណាមួយ | ២ ០០០ ០០០ |
| ១០៤ | - | បទល្មើសត្រូវបានពិន័យរួច តែនៅបន្តប្រព្រឹត្តជាថ្មី (ករណីមិនរាងចាល តាមមាត្រា៦៤) | ពិន័យទ្វេដង |
| | ១៥- | ការផ្សព្វផ្សាយ ឬប្រើប្រាស់វិញ្ញាបនបត្រវាយតម្លៃទទួលស្គាល់ ឬវិញ្ញាបនបត្រចុះបញ្ជីក្លែងបន្លំ (មាត្រា៥៧ ថ្មី) | |
| ១០៥ | - | ផាកពិន័យលើកទី១ | ២ ០០០ ០០០ |
| ១០៦ | - | ផាកពិន័យលើកទី២ (ករណីមិនគោរពតាមកិច្ចសន្យាលើកទី១) | ៤ ០០០ ០០០ |
| ១០៧ | - | ផាកពិន័យលើកទី៣ (ករណីមិនគោរពតាមកិច្ចសន្យាលើកទី២) | ៦ ០០០ ០០០ |
| ១០៨ | - | ផាកពិន័យលើកចុងក្រោយ (ករណីមិនរៀងចាល តាមមាត្រា៦៤) | ១២ ០០០ ០០០ |
| | ១៦- | ការផ្សព្វផ្សាយ ឬប្រើប្រាស់វិញ្ញាបនបត្រវាយតម្លៃទទួលស្គាល់ ឬវិញ្ញាបនបត្រចុះបញ្ជីនៅពេលដែលវិញ្ញាបនបត្រនេះត្រូវព្យួរទុក ឬដកហូត (មាត្រា[illegible]) | |
| ១០៩ | - | ផាកពិន័យលើកទី១ | ២ ០០០ ០០០ |
| ១១០ | - | ផាកពិន័យលើកទី២ (ករណីមិនគោរពតាមកិច្ចសន្យាលើកទី១) | ១០ ០០០ ០០០ |
| ១១១ | - | ផាកពិន័យលើកទី៣ (ករណីមិនគោរពតាមកិច្ចសន្យាលើកទី២) | ២៤ ០០០ ០០០ |
| ១១២ | - | ផាកពិន័យលើកចុងក្រោយ (ករណីមិនរៀងចាល តាមមាត្រា៦៤) | ៤៨ ០០០ ០០០ |

| លេខរៀងបទល្មើស | | ប្រភេទបទល្មើស | កម្រិតទឹកប្រាក់ដែលត្រូវពិន័យ (រៀល) |
|---|---|---|---|
| | ឃ. | **បទល្មើសដែលចែងក្នុងច្បាប់ ស្ដីពីការហាមឃាត់អាវុធគីមី** | |
| | | ការផលិត ទិញ លក់ កាន់កាប់ កែច្នៃ ទទួល ផ្ទេរ រក្សាទុក ដឹកជញ្ជូនឆ្លងកាត់ ឬប្រើប្រាស់សារធាតុគីមីក្នុងវិស័យឧស្សាហកម្ម ដោយគ្មានលិខិតអនុញ្ញាត (មាត្រា២៨) | |
| ១១៣ | - | តម្លៃនាំចូល ឬនាំចេញសារធាតុគីមី ក្រោម ៥០លានរៀល | ២០ ០០០ ០០០ |
| ១១៤ | - | តម្លៃនាំចូល ឬនាំចេញសារធាតុគីមី ចាប់ពី ៥០លានរៀល ដល់ក្រោម ១០០លានរៀល | ៣០ ០០០ ០០០ |
| ១១៥ | - | តម្លៃនាំចូល ឬនាំចេញសារធាតុគីមី ចាប់ពី ១០០លានរៀល ដល់ក្រោម ២០០លានរៀល | ៤០ ០០០ ០០០ |
| ១១៦ | - | តម្លៃនាំចូល ឬនាំចេញសារធាតុគីមី ចាប់ពី ២០០លានរៀល ឡើងទៅ | ៥០ ០០០ ០០០ |
| | ង. | **បទល្មើសដែលចែងក្នុងច្បាប់ ស្ដីពីការគ្រប់គ្រងអាស៊ីដខ្លាំង** | |
| | ១- | អំពើផលិត កែច្នៃ នាំចូល នាំចេញ វេចខ្ចប់ ដឹកជញ្ជូន យកតាមខ្លួន ចែកចាយ លក់ ទិញ រក្សាទុក និងប្រើប្រាស់អាស៊ីដខ្លាំងគ្រប់ប្រភេទ ដោយគ្មានអាជ្ញាបណ្ណ ឬ លិខិតអនុញ្ញាត ឬ មិនគោរពតាមការកំណត់របស់បទដ្ឋានគតិយុត្ត ដែលមានទម្ងន់ក្រោម ៥០០ក្រាម (មាត្រា១៤ ចំណុចទី១) | |
| ១១៧ | - | អាស៊ីដខ្លាំងមានទម្ងន់ ក្រោម ១០០ក្រាម | ៥០០ ០០០ |
| ១១៨ | - | អាស៊ីដខ្លាំងមានទម្ងន់ ចាប់ពី ១០០ក្រាម ទៅក្រោម ៣០០ក្រាម | ១ ០០០ ០០០ |
| ១១៩ | - | អាស៊ីដខ្លាំងមានទម្ងន់ ចាប់ពី ៣០០ក្រាម ទៅក្រោម ៥០០ក្រាម ឡើងទៅ | ១ ៥០០ ០០០ |
| | ២- | អំពើផលិត កែច្នៃ នាំចូល នាំចេញ វេចខ្ចប់ ដឹកជញ្ជូន យកតាមខ្លួន ចែកចាយ លក់ ទិញ រក្សាទុក និងប្រើប្រាស់អាស៊ីដខ្លាំងគ្រប់ប្រភេទ ដោយគ្មានអាជ្ញាបណ្ណ ឬលិខិតអនុញ្ញាត ឬមិនគោរពតាមការកំណត់របស់បទដ្ឋានគតិយុត្ត ដែលមានទម្ងន់ចាប់ពី ៥០០ក្រាម (មាត្រា១៤ ចំណុចទី២) | |
| ១២០ | - | អាស៊ីដខ្លាំងមានទម្ងន់ ចាប់ពី ៥០០ក្រាម ទៅក្រោម ៦០០ក្រាម | ២ ០០០ ០០០ |
| ១២១ | - | អាស៊ីដខ្លាំងមានទម្ងន់ ចាប់ពី ៦០០ក្រាម ទៅក្រោម ៧០០ក្រាម | ៤ ០០០ ០០០ |
| ១២២ | - | អាស៊ីដខ្លាំងមានទម្ងន់ ចាប់ពី ៧០០ក្រាម ទៅក្រោម ៨០០ក្រាម | ៦ ០០០ ០០០ |
| ១២៣ | - | អាស៊ីដខ្លាំងមានទម្ងន់ ចាប់ពី ៨០០ក្រាម ទៅក្រោម ១ ០០០ក្រាម | ៨ ០០០ ០០០ |
| ១២៤ | - | អាស៊ីដខ្លាំងមានទម្ងន់ ចាប់ពី ១ ០០០ក្រាម ឡើងទៅ | ១០ ០០០ ០០០ |
| | ៣- | អំពើផលិតម្ហូបអាហារ ឬការអនុញ្ញាតឱ្យផលិតម្ហូបអាហារ ដោយប្រើអាស៊ីដខ្លាំងខុសពីបទដ្ឋានបច្ចេកទេស (មាត្រា២៣) | |
| ១២៥ | - | ការប្រើប្រាស់អាស៊ីដខ្លាំងខុសបទដ្ឋានបច្ចេកទេសលើផលិតម្ហូបអាហារក្នុងភោជនីយដ្ឋាន | ៥ ០០០ ០០០ |
| ១២៦ | - | ការប្រើប្រាស់ក្នុងរោងចក្រ សហគ្រាស ឬសិប្បកម្មផលិតម្ហូបអាហារ | ១០ ០០០ ០០០ |
| | ច. | **បទល្មើសដែលចែងក្នុងច្បាប់ ស្ដីពីមាត្រាសាស្ត្រកម្ពុជា** | |
| | ច.១ | **ពិន័យអន្តរការណ៍ជាប្រាក់ និងក្នុងករណីមិនរាងចាល ត្រូវពិន័យជាប្រាក់ទ្វេដង ចំពោះ**<br>**១. ជនណាដែលប្រើប្រាស់ ឬកាន់កាប់សម្រាប់ប្រើប្រាស់ក្នុងសកម្មភាពពាណិជ្ជកម្មនូវឧបករណ៍មាត្រាសាស្ត្រ ដែលមិនមានពាណិជ្ជសញ្ញា (ក្នុងមួយគ្រឿង)(មាត្រា៣៩)**<br>**២. ជនណាដែលប្រើប្រាស់ ឬកាន់កាប់សម្រាប់ប្រើប្រាស់ក្នុងសកម្មភាពពាណិជ្ជកម្ម ឬលក់ ដាក់តាំងដើម្បីលក់ ឬដើម្បីចែកចាយនូវឧបករណ៍មាត្រាសាស្ត្រ ដែលមិនបានដាក់សញ្ញាត្រួតពិនិត្យដោយមន្ត្រីត្រួតពិនិត្យ (មាត្រា៤១)** | |
| | ១- | ផ្នែកទម្ងន់ | |
| | ១.១- | ជញ្ជីងមេកានិក | |
| ១២៧ | - | សម្រាប់ជញ្ជីងថ្លឹងវត្ថុមានតម្លៃ | ៥០០ ០០០ |
| ១២៨ | - | ទម្ងន់តិចជាង ១គីឡូក្រាម ដល់ ១ ០០០គីឡូក្រាម | ២០០ ០០០ |
| ១២៩ | - | ទម្ងន់លើសពី ១ ០០០គីឡូក្រាម ដល់ ៤០ ០០០គីឡូក្រាម | ៤០០ ០០០ |
| ១៣០ | - | ទម្ងន់លើសពី ៤០ ០០០គីឡូក្រាម | ៥០០ ០០០ |
| | ១.២- | ជញ្ជីងឌីជីថល | |
| ១៣១ | - | សម្រាប់ជញ្ជីងថ្លឹងវត្ថុមានតម្លៃ | ៥០០ ០០០ |
| ១៣២ | - | ទម្ងន់តិចជាង ១គីឡូក្រាម ដល់ ១ ០០០គីឡូក្រាម | ២០០ ០០០ |
| ១៣៣ | - | ទម្ងន់លើសពី ១ ០០០គីឡូក្រាម ដល់ ៤០ ០០០គីឡូក្រាម | ៤០០ ០០០ |
| ១៣៤ | - | ទម្ងន់លើសពី ៤០ ០០០គីឡូក្រាម | ៥០០ ០០០ |
| | ២- | ផ្នែកចំណុះ | |
| ១៣៥ | - | ចំណុះតិចជាង ១លីត្រ ដល់ ២ ០០០លីត្រ | ១០០ ០០០ |
| ១៣៦ | - | ចំណុះលើសពី ២ ០០០លីត្រ ដល់ ២៣ ០០០លីត្រ | ៣០០ ០០០ |
| ១៣៧ | - | ចំណុះលើសពី ២៣ ០០០លីត្រ | ៥០០ ០០០ |

| លេខរៀងបទល្មើស | | ប្រភេទបទល្មើស | កម្រិតទឹកប្រាក់ដែលត្រូវពិន័យ (រៀល) |
|---|---|---|---|
| | ៣- | ឧបករណ៍បែងចែកវត្ថុរាវ (ប្រេងឥន្ធនៈ និងហ្គាស) | |
| ១៣៨ | - | ដៃបាញ់ប្រេងចំនួន១ (តាមស្ថានីយ) | ៥០០ ០០០ |
| ១៣៩ | - | ធុងហ្គាស (អប្បបរមា ៧គីឡូក្រាម) | ១០០ ០០០ |
| ១៤០ | - | ធុងហ្គាស (១៥គីឡូក្រាម) | ៣០០ ០០០ |
| ១៤១ | - | ធុងហ្គាស (លើសពី ១៥គីឡូក្រាម) | ៥០០ ០០០ |
| ១៤២ | - | ដៃវ៉ែប្លមប្រេងចំនួន១ | ២០០ ០០០ |
| ១៤៣ | - | ឧបករណ៍បែងចែក (flow meter) ប្រេងឥន្ធនៈ និងឧស្ម័ន | ៥០០ ០០០ |
| ១៤៤ | - | កុងទ័រចែកចាយឧស្ម័នឥន្ធនៈរាវ (១ដៃបាញ់) | ៥០០ ០០០ |
| | ៤- | កុងទ័រទឹក (ក្រុមហ៊ុនចែកចាយ ឬអ្នកផ្គត់ផ្គង់កុងទ័រទឹក) | |
| ១៤៥ | - | ឧបករណ៍ដែលមានអង្កត់ផ្ចិតតូចជាង ឬស្មើ ៣២មីល្លីម៉ែត្រ | ២០០ ០០០ |
| ១៤៦ | - | ឧបករណ៍ដែលមានអង្កត់ផ្ចិតលើសពី ៣២មីល្លីម៉ែត្រ ដល់ ១០០មីល្លីម៉ែត្រ | ៤០០ ០០០ |
| ១៤៧ | - | ឧបករណ៍ដែលមានអង្កត់ផ្ចិតលើសពី ១០០មីល្លីម៉ែត្រ | ៥០០ ០០០ |
| | ៥- | ឧបករណ៍វាស់ប្រវែង | |
| ១៤៨ | - | មីក្រូម៉ែត្រ / កុងទ័រតាក់ស៊ី | ៥០០ ០០០ |
| ១៤៩ | - | ប្រវែងតូចជាង ឬស្មើ ១០ម៉ែត្រ (ប្រើក្នុងឧស្សាហកម្ម) | ២០០ ០០០ |
| ១៥០ | - | ប្រវែងលើសពី ១០ម៉ែត្រ | ៥០០ ០០០ |
| | ៦- | ឧបករណ៍វាស់សីតុណ្ហភាព | |
| ១៥១ | - | សីតុណ្ហភាពតូចជាង ឬស្មើ ៩០អង្សាសេ (ប្រើក្នុងអាជីវកម្ម និងសេវាកម្មទូទៅ) | ២០០ ០០០ |
| ១៥២ | - | សីតុណ្ហភាពចាប់ពី - ៥អង្សាសេ ដល់ ២០០អង្សាសេ (ប្រើក្នុងឧស្សាហកម្ម) | ២០០ ០០០ |
| ១៥៣ | - | សីតុណ្ហភាពចាប់ពី - ៣០អង្សាសេ ដល់ ២០០អង្សាសេ (ប្រើក្នុងឧស្សាហកម្ម) | ៤០០ ០០០ |
| ១៥៤ | - | សីតុណ្ហភាពលើសពី ២០០អង្សាសេ (ប្រើក្នុងឧស្សាហកម្ម) | ៥០០ ០០០ |
| | ៧- | ឧបករណ៍វាស់ថាមពល | |
| | ៧.១- | ឧបករណ៍វាស់អគ្គិសនី (ជាតម្រូវការរបស់អតិថិជន) | |
| ១៥៥ | - | វ៉ុលម៉ែត្រ(V) / អំពែម៉ែត្រ អូមម៉ែត្រ វ៉ាត់ | ៥០០ ០០០ |
| | ៧.២- | កុងទ័រអគ្គិសនីម៉ូណូហ្វា (ក្រុមហ៊ុនចែកចាយ ឬ អ្នកផ្គត់ផ្គង់កុងទ័រអគ្គិសនី) | |
| ១៥៦ | - | ចាប់ពី ៥អំពែ ដល់ ៣០អំពែ | ៥០០ ០០០ |
| ១៥៧ | - | លើសពី ៣០អំពែ ដល់ ១០០អំពែ | ១៥០ ០០០ |
| ១៥៨ | - | លើសពី ១០០អំពែ | ៣០០ ០០០ |
| | ៧.៣- | កុងទ័រអគ្គិសនីទ្រីហ្វា (ក្រុមហ៊ុនចែកចាយ ឬ អ្នកផ្គត់ផ្គង់កុងទ័រអគ្គិសនី) | |
| ១៥៩ | - | ចាប់ពី ៥អំពែ ដល់ ៣០អំពែ | ១០០ ០០០ |
| ១៦០ | - | លើសពី ៣០អំពែ ដល់ ១០០អំពែ | ៣០០ ០០០ |
| ១៦១ | - | លើសពី ១០០អំពែ | ៥០០ ០០០ |
| | ៨- | ឧបករណ៍វាស់សម្ពាធ (ប្រើប្រាស់នៅរោងចក្រ សហគ្រាស) | |
| ១៦២ | - | សម្ពាធតូចជាង ឬស្មើ ៣០គីឡូប៉ាស្កាល់ | ១៥០ ០០០ |
| ១៦៣ | - | សម្ពាធលើសពី ៣០គីឡូប៉ាស្កាល់ ដល់ ១៥០គីឡូប៉ាស្កាល់ | ៣០០ ០០០ |
| ១៦៤ | - | សម្ពាធលើសពី ១៥០គីឡូប៉ាស្កាល់ | ៥០០ ០០០ |
| ១៦៥ | ៩- | ម៉ាស៊ីនតេស្តពណ៌ក្រណាត់ / ម៉ាស៊ីនវាស់លោហៈធាតុ (ប្រើប្រាស់នៅក្នុងរោងចក្រ សហគ្រាស) | ៥០០ ០០០ |
| | ៦.២ | **ពិន័យអន្តរការណ៍ជាប្រាក់ និងក្នុងករណីមិនរាងចាល ត្រូវពិន័យជាប្រាក់ទ្វេដង ចំពោះជនណាដែលលក់ ដាក់តាំងដើម្បីលក់ ដើម្បីចែកចាយ ឬដើម្បីជួលនូវឧបករណ៍មាត្រាសាស្ត្រដែលមិនមានពាណិសញ្ញា (ក្នុងមួយគ្រឿង) (មាត្រា៤០)** | |
| | ១- | ផ្នែកទម្ងន់ | |
| | ១.១- | ជញ្ជីងមេកានិក | |
| ១៦៦ | - | សម្រាប់ជញ្ជីងថ្លឹងវត្ថុមានតម្លៃ | ៥០០ ០០០ |

| លេខរៀងបទល្មើស | | ប្រភេទបទល្មើស | កម្រិតទឹកប្រាក់ដែលត្រូវពិន័យ (រៀល) |
|---|---|---|---|
| ១៦៧ | - | ទម្ងន់តិចជាង ១គីឡូក្រាម ដល់ ១ ០០០គីឡូក្រាម | ២០០ ០០០ |
| ១៦៨ | - | ទម្ងន់លើសពី ១ ០០០គីឡូក្រាម ដល់ ៤០ ០០០គីឡូក្រាម | ៤០០ ០០០ |
| ១៦៩ | - | ទម្ងន់លើសពី ៤០ ០០០គីឡូក្រាម | ៥០០ ០០០ |
| | ១.២- | ជញ្ជីងឌីជីថល | |
| ១៧០ | - | សម្រាប់ជញ្ជីងថ្លឹងវត្ថុមានតម្លៃ | ៥០០ ០០០ |
| ១៧១ | - | ទម្ងន់តិចជាង ១គីឡូក្រាម ដល់ ១ ០០០គីឡូក្រាម | ២០០ ០០០ |
| ១៧២ | - | ទម្ងន់លើសពី ១ ០០០គីឡូក្រាម ដល់ ៤០ ០០០គីឡូក្រាម | ៤០០ ០០០ |
| ១៧៣ | - | ទម្ងន់លើសពី ៤០ ០០០គីឡូក្រាម | ៥០០ ០០០ |
| | ២- | ផ្នែកចំណុះ | |
| ១៧៤ | - | ចំណុះតិចជាង ១លីត្រ ដល់ ២ ០០០លីត្រ | ១០០ ០០០ |
| ១៧៥ | - | ចំណុះលើសពី ២ ០០០លីត្រ ដល់ ២៣ ០០០លីត្រ | ៣០០ ០០០ |
| ១៧៦ | - | ចំណុះលើសពី ២៣ ០០០លីត្រ | ៥០០ ០០០ |
| | ៣- | ឧបករណ៍បែងចែកវត្ថុរាវ (ប្រេងឥន្ធនៈ និងហ្គាស) | |
| ១៧៧ | - | ដៃបាញ់ប្រេងចំនួន១ (តាមស្ថានីយ) | ៥០០ ០០០ |
| ១៧៨ | - | ធុងហ្គាស (អប្បបរមា ៧គីឡូក្រាម) | ១០០ ០០០ |
| ១៧៩ | - | ធុងហ្គាស (១៥គីឡូក្រាម) | ៣០០ ០០០ |
| ១៨០ | - | ធុងហ្គាស (លើសពី ១៥គីឡូក្រាម) | ៥០០ ០០០ |
| ១៨១ | - | ដៃវែប្លមប្រេងចំនួន១ | ២០០ ០០០ |
| ១៨២ | - | ឧបករណ៍បែងចែក (flow meter) ប្រេងឥន្ធនៈ និងឧស្ម័ន | ៥០០ ០០០ |
| ១៨៣ | - | កុងទ័រចែកចាយឧស្ម័នឥន្ធនៈរាវ (១ដៃបាញ់) | ៥០០ ០០០ |
| | ៤- | កុងទ័រទឹក (ក្រុមហ៊ុនចែកចាយ ឬអ្នកផ្គត់ផ្គង់កុងទ័រទឹក) | |
| ១៨៤ | - | ឧបករណ៍ដែលមានអង្កត់ផ្ចិតតូចជាង ឬស្មើ ៣២មីលីម៉ែត្រ | ២០០ ០០០ |
| ១៨៥ | - | ឧបករណ៍ដែលមានអង្កត់ផ្ចិតលើសពី ៣២មីលីម៉ែត្រ ដល់ ១០០មីលីម៉ែត្រ | ៤០០ ០០០ |
| ១៨៦ | - | ឧបករណ៍ដែលមានអង្កត់ផ្ចិតលើសពី ១០០មីលីម៉ែត្រ | ៥០០ ០០០ |
| | ៥- | ឧបករណ៍វាស់ប្រវែង | |
| ១៨៧ | - | មីត្រូម៉ែត្រ / កុងទ័រតាក់ស៊ី | ៥០០ ០០០ |
| ១៨៨ | - | ប្រវែងតូចជាង ឬស្មើ ១០ម៉ែត្រ (ប្រើក្នុងឧស្សាហកម្ម) | ២០០ ០០០ |
| ១៨៩ | - | ប្រវែងលើសពី ១០ម៉ែត្រឡើង | ៥០០ ០០០ |
| | ៦- | ឧបករណ៍វាស់សីតុណ្ហភាព | |
| ១៩០ | - | សីតុណ្ហភាពតូចជាង ឬ ស្មើ ៥០អង្សាសេ (ប្រើក្នុងអាជីវកម្ម និងសេវាកម្មទូទៅ) | ២០០ ០០០ |
| ១៩១ | - | សីតុណ្ហភាពចាប់ពី - ៥អង្សាសេ ដល់ ២០០អង្សាសេ (ប្រើក្នុងឧស្សាហកម្ម) | ២០០ ០០០ |
| ១៩២ | - | សីតុណ្ហភាពចាប់ពី - ៣០អង្សាសេ ដល់ ២០០អង្សាសេ (ប្រើក្នុងឧស្សាហកម្ម) | ៤០០ ០០០ |
| ១៩៣ | - | សីតុណ្ហភាពលើសពី ២០០អង្សាសេ (ប្រើក្នុងឧស្សាហកម្ម) | ៥០០ ០០០ |
| | ៧- | **ឧបករណ៍វាស់ថាមពល** | |
| | ៧.១- | ឧបករណ៍វាស់អគ្គិសនី (ជាតម្រូវការរបស់អតិថិជន) | |
| ១៩៤ | - | វ៉ុលម៉ែត្រ(V) / អំពែម៉ែត្រ អូមម៉ែត្រ វ៉ាត់ | ៥០០ ០០០ |
| | ៧.២- | កុងទ័រអគ្គិសនីម៉ូណូហ្វា (ក្រុមហ៊ុនចែកចាយ ឬ អ្នកផ្គត់ផ្គង់កុងទ័រអគ្គិសនី) | |
| ១៩៥ | - | ចាប់ពី ៥អំពែ ដល់ ៣០អំពែ | ៥០០ ០០០ |
| ១៩៦ | - | លើសពី ៣០អំពែ ដល់ ១០០អំពែ | ១៥០ ០០០ |
| ១៩៧ | - | លើសពី ១០០អំពែ | ៣០០ ០០០ |

| លេខរៀងបទល្មើស | | ប្រភេទបទល្មើស | កម្រិតទឹកប្រាក់ដែលត្រូវពិន័យ (រៀល) |
|---|---|---|---|
| | ៧.៣- | កុងទ័រអគ្គិសនីទ្រីហ្វា (ក្រុមហ៊ុនចែកចាយ ឬ អ្នកផ្គត់ផ្គង់កុងទ័រអគ្គិសនី) | |
| ១៩៨ | - | ចាប់ពី ៥អំពែ ដល់ ៣០អំពែ | ១០០ ០០០ |
| ១៩៩ | - | លើសពី ៣០អំពែ ដល់ ១០០អំពែ | ៣០០ ០០០ |
| ២០០ | - | លើសពី ១០០អំពែ | ៥០០ ០០០ |
| | ៨- | ឧបករណ៍វាស់សម្ពាធ (ប្រើប្រាស់នៅរោងចក្រ សហគ្រាស) | |
| ២០១ | - | សម្ពាធតូចជាង ឬស្មើ ៣០គីឡូប៉ាស្កាល់ | ១៥០ ០០០ |
| ២០២ | - | សម្ពាធលើសពី ៣០គីឡូប៉ាស្កាល់ ដល់ ១៥០គីឡូប៉ាស្កាល់ | ៣០០ ០០០ |
| ២០៣ | - | សម្ពាធលើសពី ១៥០គីឡូប៉ាស្កាល់ | ៥០០ ០០០ |
| ២០៤ | ៩- | ម៉ាស៊ីនតេស្តពណ៌ក្រណាត់ / ម៉ាស៊ីនវាវលោហៈធាតុ (ប្រើប្រាស់នៅក្នុងរោងចក្រ សហគ្រាស) | ៥០០ ០០០ |
| | ច.៣ | **ពិន័យអន្តរការណ៍ជាប្រាក់ និងក្នុងករណីមិនរាងចាល ត្រូវពិន័យជាប្រាក់ទ្វេដង ចំពោះជនណាដែល (មាត្រា៤២)** | |
| | ១- | នាំចូល និង/ឬផលិតឧបករណ៍មាត្រាសាស្ត្រ ដោយមិនអនុវត្តតាមគំរូដែលអនុម័តពីទម្ងន់ និងរង្វាស់រង្វាល់ ឬគ្មានការអនុម័តគំរូ | |
| ២០៥ | - | តម្លៃឧបករណ៍នាំចូលតិចជាង ឬស្មើ ៥លានរៀល | ១ ០០០ ០០០ |
| ២០៦ | - | តម្លៃឧបករណ៍នាំចូលលើសពី ៥លានរៀល ដល់ ៥០លានរៀល | ២ ០០០ ០០០ |
| ២០៧ | - | តម្លៃឧបករណ៍នាំចូលលើសពី ៥០លានរៀល ដល់ ៥០០លានរៀល | ៣ ០០០ ០០០ |
| ២០៨ | - | តម្លៃឧបករណ៍នាំចូលលើសពី ៥០០លានរៀល | ៥ ០០០ ០០០ |
| | ២- | ផលិត និង/ឬជួសជុលឧបករណ៍មាត្រាសាស្ត្រ ដែលគ្មានអាជ្ញាបណ្ណចេញដោយមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ | |
| ២០៩ | - | ដើមទុនតិចជាង ឬស្មើ ៣ ០០០ដុល្លារអាម៉េរិក | ១ ០០០ ០០០ |
| ២១០ | - | ដើមទុនលើសពី ៣ ០០០ដុល្លារអាម៉េរិក ដល់ ៥០ ០០០ដុល្លារអាម៉េរិក | ២ ០០០ ០០០ |
| ២១១ | - | ដើមទុនលើសពី ៥០ ០០០ដុល្លារអាម៉េរិក ដល់ ២ ០០០ ០០០ដុល្លារអាម៉េរិក | ៣ ០០០ ០០០ |
| ២១២ | - | ដើមទុនលើសពី ២ ០០០ ០០០ដុល្លារអាម៉េរិក | ៥ ០០០ ០០០ |
| | ៣- | កាន់អាជ្ញាបណ្ណ តែបំពានលើលក្ខខណ្ឌ ដែលមានចែងនៅក្នុងអាជ្ញាបណ្ណ | |
| ២១៣ | - | ដើមទុនតិចជាង ឬស្មើ ៣ ០០០ដុល្លារអាម៉េរិក | ១ ០០០ ០០០ |
| ២១៤ | - | ដើមទុនលើសពី ៣ ០០០ដុល្លារអាម៉េរិក ដល់ ៥០ ០០០ដុល្លារអាម៉េរិក | ២ ០០០ ០០០ |
| ២១៥ | - | ដើមទុនលើសពី ៥០ ០០០ដុល្លារអាម៉េរិក ដល់ ២ ០០០ ០០០ដុល្លារអាម៉េរិក | ៣ ០០០ ០០០ |
| ២១៦ | - | ដើមទុនលើសពី ២ ០០០ ០០០ដុល្លារអាម៉េរិក | ៥ ០០០ ០០០ |
| | ច.៤ | **ពិន័យអន្តរការណ៍ជាប្រាក់ និងក្នុងករណីមិនរាងចាល ត្រូវពិន័យជាប្រាក់ទ្វេដង ចំពោះជនណាដែល (មាត្រា៤៤)** | |
| | ច.៤.១ | ប្រើប្រាស់ ឬកាន់កាប់សម្រាប់ប្រើប្រាស់ក្នុងសកម្មភាពពាណិជ្ជកម្ម ឬលក់ដាក់តាំង និងដើម្បីលក់ ឬដើម្បីចែកចាយនូវឧបករណ៍មាត្រាសាស្ត្រ ដែលមានពាណិជ្ជសញ្ញា ដែលខ្លួនបានដឹងថាជាពាណិជ្ជសញ្ញាក្លែងក្លាយ | |
| | ១- | ផ្នែកទម្ងន់ | |
| | ១.១- | ជញ្ជីងមេកានិក | |
| ២១៧ | - | សម្រាប់ជញ្ជីងថ្លឹងវត្ថុមានតម្លៃ | ៥ ០០០ ០០០ |
| ២១៨ | - | ទម្ងន់តិចជាង ១គីឡូក្រាម ដល់ ១ ០០០គីឡូក្រាម | ២ ០០០ ០០០ |
| ២១៩ | - | ទម្ងន់លើសពី ១ ០០០គីឡូក្រាម ដល់ ៤០ ០០០គីឡូក្រាម | ៤ ០០០ ០០០ |
| ២២០ | - | ទម្ងន់លើសពី ៤០ ០០០គីឡូក្រាម | ៥ ០០០ ០០០ |
| | ១.២- | ជញ្ជីងឌីជីថល | |
| ២២១ | - | សម្រាប់ជញ្ជីងថ្លឹងវត្ថុមានតម្លៃ | ៥ ០០០ ០០០ |
| ២២២ | - | ទម្ងន់តិចជាង ១គីឡូក្រាម ដល់ ១ ០០០គីឡូក្រាម | ២ ០០០ ០០០ |
| ២២៣ | - | ទម្ងន់លើសពី ១ ០០០គីឡូក្រាម ដល់ ៤០ ០០០គីឡូក្រាម | ៤ ០០០ ០០០ |
| ២២៤ | - | ទម្ងន់លើសពី ៤០ ០០០គីឡូក្រាម | ៥ ០០០ ០០០ |

| លេខរៀងបទល្មើស | | ប្រភេទបទល្មើស | កម្រិតទឹកប្រាក់ដែលត្រូវពិន័យ (រៀល) |
|---|---|---|---|
| | ២- | ផ្នែកចំណុះ | |
| ២២៥ | - | ចំណុះតិចជាង ១លីត្រ ដល់ ២ ០០០លីត្រ | ១ ០០០ ០០០ |
| ២២៦ | - | ចំណុះលើសពី ២ ០០០លីត្រ ដល់ ២៣ ០០០លីត្រ | ៣ ០០០ ០០០ |
| ២២៧ | - | ចំណុះលើសពី ២៣ ០០០លីត្រ | ៥ ០០០ ០០០ |
| | ៣- | ឧបករណ៍បែងចែកវត្ថុរាវ (ប្រេងឥន្ធនៈ និងហ្គាស) | |
| ២២៨ | - | ដៃបាញ់ប្រេងចំនួន១ (តាមស្ថានីយ) | ៥ ០០០ ០០០ |
| ២២៩ | - | ធុងហ្គាស (អប្បបរមា ៧គីឡូក្រាម) | ១ ០០០ ០០០ |
| ២៣០ | - | ធុងហ្គាស (១៥គីឡូក្រាម) | ៣ ០០០ ០០០ |
| ២៣១ | - | ធុងហ្គាស (លើសពី ១៥គីឡូក្រាម) | ៥ ០០០ ០០០ |
| ២៣២ | - | ដែរវៃប្ដូរប្រេងចំនួន១ | ២ ០០០ ០០០ |
| ២៣៣ | - | ឧបករណ៍បែងចែក (flow meter) ប្រេងឥន្ធនៈ និងឧស្ម័ន | ៥ ០០០ ០០០ |
| ២៣៤ | - | កុងទ័រចែកចាយឧស្ម័នឥន្ធនៈរាវ (១ដៃបាញ់) | ៥០០ ០០០ |
| | ៤- | កុងទ័រទឹក (ក្រុមហ៊ុនចែកចាយ ឬអ្នកផ្គត់ផ្គង់កុងទ័រទឹក) | |
| ២៣៥ | - | ឧបករណ៍ដែលមានអង្កត់ផ្ចិតតូចជាង ឬស្មើ ៣២មីល្លីម៉ែត្រ | ២ ០០០ ០០០ |
| ២៣៦ | - | ឧបករណ៍ដែលមានអង្កត់ផ្ចិតលើសពី ៣២មីល្លីម៉ែត្រ ដល់ ១០០មីល្លីម៉ែត្រ | ៤ ០០០ ០០០ |
| ២៣៧ | - | ឧបករណ៍ដែលមានអង្កត់ផ្ចិតលើសពី ១០០មីល្លីម៉ែត្រ | ៥ ០០០ ០០០ |
| | ៥- | ឧបករណ៍វាស់ប្រវែង | |
| ២៣៨ | - | មីក្រូម៉ែត្រ / កុងទ័រតាក់ស៊ី | ៥ ០០០ ០០០ |
| ២៣៩ | - | ប្រវែងតូចជាង ឬស្មើ ១០ម៉ែត្រ (ប្រើក្នុងឧស្សាហកម្ម) | ២ ០០០ ០០០ |
| ២៤០ | - | ប្រវែងលើសពី ១០ម៉ែត្រ | ៥ ០០០ ០០០ |
| | ៦- | ឧបករណ៍វាស់សីតុណ្ហភាព | |
| ២៤១ | - | សីតុណ្ហភាពតូចជាង ឬស្មើ ៥០អង្សាសេ (ប្រើក្នុងអាជីវកម្ម និងសេវាកម្មទូទៅ) | ២ ០០០ ០០០ |
| ២៤២ | - | សីតុណ្ហភាពចាប់ពី - ៥អង្សាសេ ដល់ ២០០អង្សាសេ (ប្រើក្នុងឧស្សាហកម្ម) | ២ ០០០ ០០០ |
| ២៤៣ | - | សីតុណ្ហភាពចាប់ពី - ៣០អង្សាសេ ដល់ ២០០អង្សាសេ (ប្រើក្នុងឧស្សាហកម្ម) | ៤ ០០០ ០០០ |
| ២៤៤ | - | សីតុណ្ហភាពលើសពី ២០០អង្សាសេ (ប្រើក្នុងឧស្សាហកម្ម) | ៥ ០០០ ០០០ |
| | ៧- | ឧបករណ៍វាស់ថាមពល | |
| | ៧.១- | ឧបករណ៍វាស់អគ្គិសនី (ជាតម្រូវការរបស់អតិថិជន) | |
| ២៤៥ | - | វ៉ុលម៉ែត្រ(V) / អំពែម៉ែត្រ អូមម៉ែត្រ វ៉ាត់ | ៥ ០០០ ០០០ |
| | ៧.២- | កុងទ័រអគ្គិសនីម៉ូណូហ្វា (ក្រុមហ៊ុនចែកចាយ ឬ អ្នកផ្គត់ផ្គង់កុងទ័រអគ្គិសនី) | |
| ២៤៦ | - | ចាប់ពី ៥អំពែ ដល់ ៣០អំពែ | ៥ ០០០ ០០០ |
| ២៤៧ | - | លើសពី ៣០អំពែ ដល់ ១០០អំពែ | ១ ៥០០ ០០០ |
| ២៤៨ | - | លើសពី ១០០អំពែ | ៣ ០០០ ០០០ |
| | ៧.៣- | កុងទ័រអគ្គិសនីទ្រីហ្វា (ក្រុមហ៊ុនចែកចាយ ឬ អ្នកផ្គត់ផ្គង់កុងទ័រអគ្គិសនី) | |
| ២៤៩ | - | ចាប់ពី ៥អំពែ ដល់ ៣០អំពែ | ៣ ០០០ ០០០ |
| ២៥០ | - | លើសពី ៣០អំពែ ដល់ ១០០អំពែ | ៣ ០០០ ០០០ |
| ២៥១ | - | លើសពី ១០០អំពែ | ៥ ០០០ ០០០ |
| | ៨- | ឧបករណ៍វាស់សម្ពាធ (ប្រើប្រាស់នៅរោងចក្រ សហគ្រាស) | |
| ២៥២ | - | សម្ពាធតូចជាង ឬស្មើ ៣០គីឡូប៉ាស្កាល់ | ១ ៥០០ ០០០ |
| ២៥៣ | - | សម្ពាធលើសពី ៣០គីឡូប៉ាស្កាល់ ដល់ ១៥០គីឡូប៉ាស្កាល់ | ៣ ០០០ ០០០ |
| ២៥៤ | - | សម្ពាធលើសពី ១៥០គីឡូប៉ាស្កាល់ | ៥ ០០០ ០០០ |
| ២៥៥ | ៩- | ម៉ាស៊ីនពេស្តពណ៌ព្រាណាត់ / ម៉ាស៊ីនវាស់លោហៈធាតុ (ប្រើប្រាស់នៅក្នុងរោងចក្រ សហគ្រាស) | ៥ ០០០ ០០០ |

| លេខរៀងបទល្មើស | | ប្រភេទបទល្មើស | កម្រិតទឹកប្រាក់ដែលត្រូវពិន័យ (រៀល) |
|---|---|---|---|
| | ៦.៤.២ | ដកចេញ ឬប្តូរសញ្ញាត្រួតពិនិត្យ ដែលបានដាក់ដោយមន្ត្រីត្រួតពិនិត្យលើឧបករណ៍មាត្រាសាស្ត្រ ហើយដាក់បញ្ចូលសញ្ញានោះលើឧបករណ៍មាត្រាសាស្ត្រផ្សេងទៀត | |
| | ១- | ផ្នែកទម្ងន់ | |
| | ១.១- | ជញ្ជីងមេកានិក | |
| ២៥៦ | - | សម្រាប់ជញ្ជីងថ្លឹងវត្ថុមានតម្លៃ | ៥ 000 000 |
| ២៥៧ | - | ទម្ងន់តិចជាង ១គីឡូក្រាម ដល់ ១ 000គីឡូក្រាម | ២ 000 000 |
| ២៥៨ | - | ទម្ងន់លើសពី ១ 000គីឡូក្រាម ដល់ ៤០ 000គីឡូក្រាម | ៤ 000 000 |
| ២៥៩ | - | ទម្ងន់លើសពី ៤០ 000គីឡូក្រាម | ៥ 000 000 |
| | ១.២- | ជញ្ជីងឌីជីថល | |
| ២៦០ | - | សម្រាប់ជញ្ជីងថ្លឹងវត្ថុមានតម្លៃ | ៥ 000 000 |
| ២៦១ | - | ទម្ងន់តិចជាង ១គីឡូក្រាម ដល់ ១ 000គីឡូក្រាម | ២ 000 000 |
| ២៦២ | - | ទម្ងន់លើសពី ១ 000គីឡូក្រាម ដល់ ៤០ 000គីឡូក្រាម | ៤ 000 000 |
| ២៦៣ | - | ទម្ងន់លើសពី ៤០ 000គីឡូក្រាម | ៥ 000 000 |
| | ២- | ផ្នែកចំណុះ | |
| ២៦៤ | - | ចំណុះតិចជាង ១លីត្រ ដល់ ២ 000លីត្រ | ១ 000 000 |
| ២៦៥ | - | ចំណុះលើសពី ២ 000លីត្រ ដល់ ២៣ 000លីត្រ | ៣ 000 000 |
| ២៦៦ | - | ចំណុះលើសពី ២៣ 000លីត្រ | ៥ 000 000 |
| | ៣- | ឧបករណ៍បែងចែកវត្ថុរាវ (ប្រេងឥន្ធនៈ និងហ្គាស) | |
| ២៦៧ | - | ដៃបាញ់ប្រេងចំនួន១ (តាមស្ថានីយ) | ៥ 000 000 |
| ២៦៨ | - | ធុងហ្គាស (អប្បបរមា ៧គីឡូក្រាម) | ១ 000 000 |
| ២៦៩ | - | ធុងហ្គាស (១៥គីឡូក្រាម) | ៣ 000 000 |
| ២៧០ | - | ធុងហ្គាស (លើសពី ១៥គីឡូក្រាម) | ៥ 000 000 |
| ២៧១ | - | ដៃរវៃបូមប្រេងចំនួន១ | ២ 000 000 |
| ២៧២ | - | ឧបករណ៍បែងចែក (flow meter) ប្រេងឥន្ធនៈ និងឧស្ម័ន | ៥ 000 000 |
| ២៧៣ | | កុងទ័រចែកចាយឧស្ម័នឥន្ធនៈរាវ (១ដៃបាញ់) | ៥00 000 |
| | ៤- | កុងទ័រទឹក (ក្រុមហ៊ុនចែកចាយ ឬអ្នកផ្គត់ផ្គង់កុងទ័រទឹក) | |
| ២៧៤ | - | ឧបករណ៍ដែលមានអង្កត់ផ្ចិតតូចជាង ឬស្មើ ៣២មីលីម៉ែត្រ | ២ 000 000 |
| ២៧៥ | - | ឧបករណ៍ដែលមានអង្កត់ផ្ចិតលើសពី ៣២មីលីម៉ែត្រ ដល់ ១០០មីលីម៉ែត្រ | ៤ 000 000 |
| ២៧៦ | - | ឧបករណ៍ដែលមានអង្កត់ផ្ចិតលើសពី ១០០មីលីម៉ែត្រ | ៥ 000 000 |
| | ៥- | ឧបករណ៍វាស់ប្រវែង | |
| ២៧៧ | - | មីក្រូម៉ែត្រ / កុងទ័រតាក់ស៊ី | ៥ 000 000 |
| ២៧៨ | - | ប្រវែងតូចជាង ឬស្មើ ១០ម៉ែត្រ (ប្រើក្នុងឧស្សាហកម្ម) | ២ 000 000 |
| ២៧៩ | - | ប្រវែងលើសពី ១០ម៉ែត្រឡើង | ៥ 000 000 |
| | ៦- | ឧបករណ៍វាស់សីតុណ្ហភាព | |
| ២៨០ | - | សីតុណ្ហភាពតូចជាង ឬស្មើ ៥០អង្សាសេ (ប្រើក្នុងអាជីវកម្ម និងសេវាកម្មទូទៅ) | ២ 000 000 |
| ២៨១ | - | សីតុណ្ហភាពចាប់ពី - ៥អង្សាសេ ដល់ ២០០អង្សាសេ (ប្រើក្នុងឧស្សាហកម្ម) | ២ 000 000 |
| ២៨២ | - | សីតុណ្ហភាពចាប់ពី - ៣០អង្សាសេ ដល់ ២០០អង្សាសេ (ប្រើក្នុងឧស្សាហកម្ម) | ៤ 000 000 |
| ២៨៣ | - | សីតុណ្ហភាពលើសពី ២០០អង្សាសេ (ប្រើក្នុងឧស្សាហកម្ម) | ៥ 000 000 |
| | ៧- | ឧបករណ៍វាស់ថាមពល | |
| | ៧.១- | ឧបករណ៍វាស់អគ្គិសនី (ជាតម្រូវការរបស់អតិថិជន) | |
| ២៨៤ | - | វ៉ុលម៉ែត្រ(V) / អំពែម៉ែត្រ អូមម៉ែត្រ វ៉ាត់ | ៥ 000 000 |

| លេខរៀងបទល្មើស | | ប្រភេទបទល្មើស | កម្រិតទឹកប្រាក់ដែលត្រូវពិន័យ (រៀល) |
|---|---|---|---|
| | ៧.២- | កុងទ័រអគ្គិសនីម៉ូណូហ្វា (ក្រុមហ៊ុនចែកចាយ ឬ អ្នកផ្គត់ផ្គង់កុងទ័រអគ្គិសនី) | |
| ២៨៥ | - | ចាប់ពី ៥អំពែ ដល់ ៣០អំពែ | ៥០០ ០០០ |
| ២៨៦ | - | លើសពី ៣០អំពែ ដល់ ១០០អំពែ | ១ ៥០០ ០០០ |
| ២៨៧ | - | លើសពី ១០០អំពែ | ៣ ០០០ ០០០ |
| | ៧.៣- | កុងទ័រអគ្គិសនីទ្រីហ្វា (ក្រុមហ៊ុនចែកចាយ ឬ អ្នកផ្គត់ផ្គង់កុងទ័រអគ្គិសនី) | |
| ២៨៨ | - | ចាប់ពី ៥អំពែ ដល់ ៣០អំពែ | ១ ០០០ ០០០ |
| ២៨៩ | - | លើសពី ៣០អំពែ ដល់ ១០០អំពែ | ៣ ០០០ ០០០ |
| ២៩០ | - | លើសពី ១០០អំពែ | ៥ ០០០ ០០០ |
| | ៨- | ឧបករណ៍វាស់សម្ពាធ (ប្រើប្រាស់នៅរោងចក្រ សហគ្រាស) | |
| ២៩១ | - | សម្ពាធតូចជាង ឬស្មើ ៣០គីឡូប៉ាស្កាល់ | ១ ៥០០ ០០០ |
| ២៩២ | - | សម្ពាធលើសពី ៣០គីឡូប៉ាស្កាល់ ដល់ ១៥០គីឡូប៉ាស្កាល់ | ៣ ០០០ ០០០ |
| ២៩៣ | - | សម្ពាធលើសពី ១៥០គីឡូប៉ាស្កាល់ | ៥ ០០០ ០០០ |
| ២៩៤ | ៩- | ម៉ាស៊ីនតេស្តពណ៌ក្រណាត់ / ម៉ាស៊ីនវាស់លោហៈធាតុ (ប្រើប្រាស់នៅក្នុងរោងចក្រ សហគ្រាស) | ៥ ០០០ ០០០ |
| | **ចំ.៥** | **ពិន័យអន្តរការណ៍ជាប្រាក់ និងក្នុងករណីមិនរាងចាល ត្រូវពិន័យជាប្រាក់ទ្វេដង ចំពោះជនណាដែលនាំចូលទំនិញ ឬអ្នកផលិតទំនិញវេចខ្ចប់ដែល (មាត្រា៤៨)**<br>**ក-នាំចូល ឬវេចខ្ចប់ទំនិញជាកញ្ចប់ផ្ទុយនឹងការតម្រូវនៃកថាខណ្ឌ នៃមាត្រា៣៣ នៃច្បាប់នេះ**<br>**ខ-ខកខានមិនបានដាក់សញ្ញាជាឯកតាដែលអនុញ្ញាតនៅលើសម្ភារវេចខ្ចប់នូវចំនួនទម្ងន់សុទ្ធ ឬវង្វាស់វង្វាល់ ដែលមានបញ្ជាក់លើសម្ភារវេចខ្ចប់នៅក្នុងកញ្ចប់នោះ**<br>**គ-ខកខានមិនបានបង្ហាញឈ្មោះ និងអាសយដ្ឋានរបស់អ្នកផលិត ឬអ្នកនាំចូល ឬសញ្ញាសម្គាល់សម្រាប់កំណត់អត្តសញ្ញាណនៃឈ្មោះ និងអាសយដ្ឋាន** | |
| | ១- | ទំនិញផលិត (មួយមុខផលិតផល) | |
| ២៩៥ | - | វាយនភ័ណ្ឌ ជាសំលៀកបំពាក់ / ជាកំរាលព្រំ | ២ ០០០ ០០០ |
| ២៩៦ | - | សម្ភារសំណង់ | ៤ ០០០ ០០០ |
| ២៩៧ | - | បរិក្ខារអគ្គិសនី អេឡិកត្រូនិច និងអុបទិក | ៤ ០០០ ០០០ |
| | ២- | ទំនិញវេចខ្ចប់ | |
| | ២.១- | ជាឧស្ម័ន ផលិតផលចំណីអាហារ និងវត្ថុរាវគ្រប់ប្រភេទ (មួយមុខផលិតផល) | |
| ២៩៨ | - | តិចជាង ឬស្មើ ៥គីឡូក្រាម ឬលីត្រ ដល់ ៣០គីឡូក្រាម ឬលីត្រ | ១ ០០០ ០០០ |
| ២៩៩ | - | លើសពី ៣០គីឡូក្រាម ឬលីត្រ ដល់ ៥០គីឡូក្រាម ឬលីត្រ | ៣ ០០០ ០០០ |
| ៣០០ | - | លើសពី ៥០គីឡូក្រាម ឬលីត្រ | ៥ ០០០ ០០០ |
| ៣០១ | - | សំណើមក្នុងគ្រាប់ធញ្ញជាតិ / ភាពភ្លឺលើគ្រាប់ធញ្ញជាតិ | ៤ ០០០ ០០០ |
| | ២.២- | ផលិតផលឱសថគ្រប់ប្រភេទ (មួយមុខផលិតផល) | |
| ៣០២ | - | ប្រភេទគ្រាប់ / ប្រភេទអំពូល / ប្រភេទទឹកស៊េរ៉ូម | ៥ ០០០ ០០០ |
| ៣០៣ | - | ផលិតផលថ្នាំជក់ និងក្រដាស | ៥ ០០០ ០០០ |
| | ២.៣- | ផលិតផលគីមី | |
| ៣០៤ | - | សាប៊ូដុំ ម្សៅសាប៊ូ គ្រឿងសំអាត ប៉ូលាគ្រឿងក្រអូប ឬគ្រឿងសំអាង | ៤ ០០០ ០០០ |
| ៣០៥ | - | ថ្នាំសម្លាប់សត្វល្អិត ឬជីគីមីកសិកម្ម | ៤ ០០០ ០០០ |
| ៣០៦ | - | ថ្នាំលាបពណ៌ វ៉ែរនី ថ្នាំទ្រនាប់ ទឹកថ្នាំបោះពុម្ព ឬម៉ាស្ទិក | ៤ ០០០ ០០០ |
| | **ចំ.៦** | **ពិន័យអន្តរការណ៍ជាប្រាក់ និងក្នុងករណីមិនរាងចាល ត្រូវពិន័យជាប្រាក់ទ្វេដង ចំពោះជនណាដែលលក់ ឬដាក់លក់នូវទំនិញវេចខ្ចប់ ដែលមិនមានដាក់ចំនួនទម្ងន់ ឬវង្វាស់វង្វាល់លើសម្ភារវេចខ្ចប់នូវឯកតាដែលមានចែងក្នុងឧបសម្ព័ន្ធទី១ និងឧបសម្ព័ន្ធទី២ (មាត្រា៤៩)** | |
| | ១- | ទំនិញផលិត (មួយមុខផលិតផល) | |
| ៣០៧ | - | វាយនភ័ណ្ឌ ជាសំលៀកបំពាក់ / ជាកំរាលព្រំ | ២ ០០០ ០០០ |
| ៣០៨ | - | សម្ភារសំណង់ | ៤ ០០០ ០០០ |
| ៣០៩ | - | បរិក្ខារអគ្គិសនី អេឡិកត្រូនិច និងអុបទិក | ៤ ០០០ ០០០ |

| លេខរៀងបទល្មើស | | ប្រភេទបទល្មើស | កម្រិតទឹកប្រាក់ដែលត្រូវពិន័យ (រៀល) |
|---|---|---|---|
| | ២- | ទំនិញវេចខ្ចប់ | |
| | ២.១- | ជាឧស្ម័ន ផលិតផលចំណីអាហារ និងវត្ថុរាវគ្រប់ប្រភេទ (មួយមុខផលិតផល) | |
| ៣១០ | - | តិចជាង ឬស្មើ ៥គីឡូក្រាម ឬលីត្រ ដល់ ៣០គីឡូក្រាម ឬលីត្រ | ១ 000 000 |
| ៣១១ | - | លើសពី ៣០គីឡូក្រាម ឬលីត្រ ដល់ ៥០គីឡូក្រាម ឬលីត្រ | ៣ 000 000 |
| ៣១២ | - | លើសពី ៥០គីឡូក្រាម ឬលីត្រ | ៥ 000 000 |
| ៣១៣ | - | សំណើមក្នុងគ្រាប់ធញ្ញជាតិ / ភាពភ្លឺលើគ្រាប់ធញ្ញជាតិ | ៤ 000 000 |
| | ២.២- | ផលិតផលឱសថគ្រប់ប្រភេទ (មួយមុខផលិតផល) | |
| ៣១៤ | - | ប្រភេទគ្រាប់ / ប្រភេទអំពូល / ប្រភេទទឹកស៊េរ៉ូម | ៥ 000 000 |
| ៣១៥ | - | ផលិតផលថ្នាំជក់ និងក្រដាស | ៥ 000 000 |
| | ២.៣- | ផលិតផលគីមី | |
| ៣១៦ | - | សាប៊ូដុំ ម្សៅសាប៊ូ គ្រឿងសំអាត ប៉ូលាគ្រឿងក្រអូប ឬគ្រឿងសំអាង | ៤ 000 000 |
| ៣១៧ | - | ថ្នាំសម្លាប់សត្វល្អិត ឬជីគីមីកសិកម្ម | ៤ 000 000 |
| ៣១៨ | - | ថ្នាំលាបពណ៌ វ៉ែរនី ថ្នាំទ្រនាប់ ទឹកថ្នាំបោះពុម្ព ឬម៉ាស្ទិក | ៤ 000 000 |
| | ៤.៧ | ពិន័យអន្តរការណ៍ជាប្រាក់ ចំពោះជនណាដែលរារាំង ឬបដិសេធមិនឱ្យមន្ត្រីត្រួតពិនិត្យអនុវត្តសិទ្ធិក្នុងប្រតិបត្តិការដែលមានចែងក្នុងច្បាប់នេះ (មាត្រា៥០) | |
| ៣១៩ | - | លើកទី១ | ១ 000 000 |
| ៣២០ | - | លើកទី២ | ៥ 000 000 |